# Universal Jurisdiction (យុត្តាធិការសកល)

១. យុត្តាធិការសកល ជាយុត្តាធិការ សម្រាប់តុលាការរដ្ឋណាមួយវិនិច្ឆ័យសេចក្តី បទល្មើសក្រោមច្បាប់អន្តរជាតិ ប្រព្រឹត្តនៅទីណាក្តី ដោយជនជាតិណាក្តី និង មិនមានជនរងគ្រោះជាប្រជាពលរដ្ឋរបស់ខ្លួនក្តី (គ្មានចំណងអ្វីទាំងអស់)។ វាជាប្រភេទយុត្តាធិការ ក្រោមវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិ សម្រាប់បទល្មើសមួយចំនួនតូច ដែលជាបទល្មើសក្រោមវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដូចជា បទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាម។ ក្រៅពីបទល្មើសទាំងនេះ មិនទាន់មានការឯកភាពជាទូទៅ លើបទល្មើសដទៃទៀត ស្ថិតក្រោមយុត្តាធិការប្រភេទនេះទេ។

២. បទល្មើសដូចជា ឧក្រិដ្ឋកម្មសង្គ្រាម អាចជាបទល្មើសប្រព្រឹត្តដោយអ្នកដឹកនាំរដ្ឋ (State Crime)។ អាស្រ័យហេតុនេះ រដ្ឋនោះអាចនឹងមិនកាត់ទោសជនដែលដល់។ បន្ថែមពីលើនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏មិនអាចមានប្រសិទ្ធភាពកាត់ទោសទាំងស្រុងបានដែរ ដោយសារ កត្តាធនធាន ឬក្របខ័ណ្ឌច្បាប់ជាដើម។ ដូចនេះវត្តមាននៃយុត្តាធិការសកល សម្រាប់រដ្ឋទីបី អាចជាជម្រើសបំពេញបន្ថែម។ រដ្ឋអនុវត្តយុត្តាធិការ ដើរតួដូចជាតំណាងសហគមន៍អន្តរជាតិ ដើម្បីជំនុំជម្រះបទឧក្រិដ្ឋ ដែលជាក្តីបារម្ភដ៏ធ្ងន់ធ្ងររបស់សហគមអន្តរជាតិ។

៣. យុត្តាធិការសកល មានពីរប្រភេទ៖ ដាច់ខាត (absolute universal jurisdiction) និង មានលក្ខខ័ណ្ឌ (conditional universal jurisdiction) ក្នុងន័យថាលុះត្រាមានវត្តមានជនល្មើសក្នុងដែនដីរដ្ឋនោះ ទើបរដ្ឋអាចប្រើយុត្តាធិការនេះបាន។ ប្រភេទខាងក្រោយនេះ ត្រូវបានបង្កើតឡើងតាមសន្ធិសញ្ញា (treaty-based jurisdiction) ដូចដែលមានចែងក្នុងមាត្រា ៧ នៃ អនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម http:// [www.measboralaws.com/detail/228](http://www.measboralaws.com/detail/228)។[1]

៤. ប្រភេទទីមួយ អាចនាំឲ្យមានការវិនិច្ឆ័យសេចក្តីគ្មានវត្តមានរបស់ជនល្មើស(trial *in absentia*) ដែលអាចខុសនឹងគោលការណ៍នៃការកាត់សេចក្តីប្រកបដោយយុត្តិធម៌។ ទោះបីជាយ៉ាងនេះក្តី ការស៊ើបអង្កេតដោយគ្មានវត្តមានជនល្មើស មិនមានជាបញ្ហាចោទទេ។ ការអនុវត្តយុត្តាធិការប្រភេទនេះ មាន

---

[1] 1. The State Party in the territory under whose jurisdiction a person alleged to have committed any offence referred to in article 4 is found shall in the cases contemplated in article 5, if <u>it does not extradite him</u>, submit the case to its <u>competent authorities for the purpose of prosecution</u>.

ភាពស្មុគ្រស្មាញ ដូចជា ការសហការប្រមូល ឬបញ្ជូនភស្តុតាង។ ករណីខ្លះ មានការចោទថា បំពានគោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋ ឬប៉ះពាល់ដល់កិច្ចការបរទេសរបស់រដ្ឋ ការជ្រើសរើសជនមុខសញ្ញាសម្រាប់ចោទប្រកាន់ ដែលពេលខ្លះអាចត្រូវបានបំពាន ដើម្បីប្រយោជន៍នយោបាយ ឬនាំឲ្យមានចលាចលក្នុងតុលាការ (judicial chaos) ដូចជា ការដណ្តើមសមត្ថកិច្ចជាដើម។

**ដកស្រង់ពី Florian Jessberger, Universal Jurisdiction in Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 555-557.**

**កំណត់សំគាល់**៖ មានការអះអាងថា បទល្មើសក្រោមច្បាប់អន្តរជាតិដូចជា អំពើប្រល័យពូជសាសន៍ កាលបើប្រព្រឹត្តហើយ បង្កទុក្ខភ័យ និងធ្វើឲ្យពិភពលោករំជួល (shocked the world)។ រដ្ឋទាំងអស់ រងគ្រោះដោយសារទង្វើនេះ។ វាបង្កើតជាកាតព្វកិច្ច *Erga Omnes* ដែលរដ្ឋទាំងអស់ត្រូវរួមគ្នាដើម្បីបង្ក្រាប មិនឲ្យជនប្រព្រឹត្តគេចពីសំណាញ់យុត្តិធម៌ និងធ្វើឲ្យពួកគេរាងចាល និងមិនមានទិន្នភាព (impunity)។ សំណុំរឿង របស់ លោក Pinochet ប្រមុខដឹកនាំរបស់ប្រទេសឈីលី នៅមុខតុលាការចក្រភពអង់គ្លេសបង្ហាញពីការអនុវត្តយុត្តាធិការសកលសូមមើល
http://www.measboralaws.com/detail/1038